ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ៣៣.០១៥.៩០៥ ធ.ន.ក

# សេចក្តីជូនដំណឹង

ក្នុងឱកាសនៃការបង្កើតសហគមន៍អាស៊ាន នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ធនាគារជាតិនៃកម្ពុជា សូមចូលរួមអបអរសាទរជាមួយរាជរដ្ឋាភិបាលកម្ពុជា និងប្រទេសជាសមាជិកអាស៊ានទាំងអស់ ដែលបានសម្រេចដោយជោគជ័យនូវការពង្រឹងសមាហរណកម្មក្នុងតំបន់ដ៏មានសារៈសំខាន់នេះ សម្រាប់ជាប្រយោជន៍ដល់ប្រជាជាតិអាស៊ានទាំងមូល ។

ដើម្បីចូលរួមអបអរសាទរចំពោះការបង្កើតសហគមន៍អាស៊ាននេះ ធនាគារជាតិនៃកម្ពុជា មានសេចក្តីសោមនស្សរីករាយ សូមជម្រាបជូនសាធារណជនឲ្យបានជ្រាបថា ធនាគារជាតិនៃកម្ពុជា បានបោះផ្សាយនូវកាសអនុស្សាវរីយ៍អាស៊ាន ដែលមានលក្ខណៈពិសេសដូចខាងក្រោម ៖

- ប្រភេទ៣.០០០រៀល
- ធ្វើពីប្រាក់ទឹក៩៩៩
- វិជ្ឈមាត្រ ៤០,៧០ម.ម
- ទម្ងន់ ១oz ឬ ៣១,១០៣ ក្រាម
- ផ្ទៃខាងមុខរូបប្រាសាទអង្គរវត្តតំណាងព្រះរាជាណាចក្រកម្ពុជានិង
- ផ្ទៃខាងក្រោយរូបទង់ជាតិអាស៊ាន និងទង់ជាតិប្រទេសជាសមាជិកទាំង ១០ ។

ធនាគារជាតិនៃកម្ពុជា នឹងចេញលក់កាសអនុស្សាវរីយ៍នេះ ចាប់ពីថ្ងៃសុក្រ ទី២៥ ខែធ្នូ ឆ្នាំ ២០១៥ ក្នុងតម្លៃ ២២៣.០០០ រៀល ក្នុង១កាស នៅធនាគារជាតិនៃកម្ពុជា ដែលមានអាសយដ្ឋាន ឡូត៍លេខ ២២-២៤ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ។

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែ ធ្នូ ឆ្នាំ ២០១៥

